**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តាងនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងខេត្ត បន្ទាយមានជ័យ**

**សាលាដំបូងខេត្ត**
**បន្ទាយមានជ័យ**

សំណុំរឿងព្រហ្មទណ្ឌលេខៈ៧៦
ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០២០
ជំនុំជម្រះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២០
សាលក្រមលេខៈ ៦៣ ខ /៨២៣
ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០២០

បានបើកសវនាការជាសាធារណៈនៅសាលាដំបូងខេត្តបន្ទាយមានជ័យ
នាថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២០ ដែលមានសមាសភាពៈ

ក្រុមប្រឹក្សាជំនុំជម្រះ

- លោកស្រី [redacted] ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ
- លោក [redacted] ជាចៅក្រមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា

តំណាងអយ្យការ

- លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តបន្ទាយមានជ័យ

ក្រឡាបញ្ជីសវនាការ

- លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តបន្ទាយមានជ័យ

**ដើម្បីជំនុំជម្រះ**

លើសំណុំរឿងព្រហ្មទណ្ឌលេខៈ៧៦ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០២០ ដែលមានជនជាប់ចោទៈ

ឈ្មោះ [redacted] **លីម** ហៅ **អាថៃ** ភេទប្រុស កើតឆ្នាំ១៩៩២ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ កំរិតវប្បធម៌ថ្នាក់ទី៩. ទីកន្លែងកំណើតភូមិ [redacted] ខេត្តសៀមរាប អាសយដ្ឋានបច្ចុប្បន្ននៅភូមិសាមគ្គីមានជ័យ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ មុខរបរកម្មករ, ឪពុកឈ្មោះ [redacted] លី (ស) ម្តាយឈ្មោះ [redacted] រុំ (រ) ជានីតិជន ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន។ **(ឃុំខ្លួនថ្ងៃទី១៨ ខែមករា ឆ្នាំ២០២០)**

ត្រូវបានដាក់ឲ្យស្ថិតក្រោមការពិនិត្យពីបទៈ **ប៉ុនប៉ងរំលោភសេពសន្ថវៈ** ប្រព្រឹត្តនៅចំណុចការដ្ឋានសំណង់បុរីដួងច័ន្ទ ភូមិសាមគ្គីមានជ័យ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី១៦ ខែមករា ឆ្នាំ២០២០ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោស តាមបញ្ញត្តិមាត្រា **២៧** និងមាត្រា**២៣៩** នៃក្រមព្រហ្មទណ្ឌ។

-ដោយមានលោកមេធាវី [redacted] ជាមេធាវីការពារក្តីជនជាប់ចោទឈ្មោះ [redacted] លីម។

-ជនរងគ្រោះឈ្មោះ [redacted] ស្រីខួច ភេទស្រី អាយុ ២០ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅភូមិសាមគ្គីមានជ័យ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។

**ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ:**

កាលពីថ្ងៃទី១៦ ខែមករា ឆ្នាំ២០២០ វេលាម៉ោងប្រហែល ២៣.០០នាទី នៅចំណុចការដ្ឋានសំណង់បុរីដួងច័ន្ទ ភូមិសាមគ្គីមានជ័យ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ មានឈ្មោះ [redacted] **លីម ហៅ អាថៃ** ភេទប្រុស បានផឹកស្រាស្រវឹង ហើយចូលក្នុងបន្ទប់របស់ឈ្មោះ [redacted] **ស្រីខួច** អាយុ ២០ឆ្នាំ និងប្តី ដែលធ្វើការសំណង់ជាមួយគ្នា ដោយបានធ្វើសកម្មភាពយកដៃអោបឈ្មោះ [redacted] ស្រីខួច និងយកដៃលូកលេងប្រដាប់ភេទ រួចឈ្មោះ [redacted] លីម បានសើយរ៉ូបរបស់ឈ្មោះ [redacted] ស្រីខួច ឡើងលើត្រឹមចង្កេះ រួចឈ្មោះ [redacted] លីម បានរុញដៃរបស់ខ្លួនចូលក្នុងប្រដាប់ភេទឈ្មោះ [redacted] ស្រីខួច ដោយឈ្មោះ [redacted] ស្រីខួច នឹកស្មានថាជាប្តីរបស់ខ្លួន ទើបមិនបានស្រែក ឬប្រកែកអ្វីឡើយ។ បន្ទាប់មកឈ្មោះ [redacted] **លីម** បានយកទូរស័ព្ទមកបញ្ចាំងមើលប្រដាប់ភេទឈ្មោះ [redacted] **ស្រីខួច** និងបានយកមាត់ទៅជញ្ជក់ប្រដាប់ភេទឈ្មោះ [redacted] ស្រីខួច និងបំរុងដោះខោរខោ តែក៏ត្រូវភ្លើងទូរស័ព្ទចាំងចំមុខឈ្មោះ [redacted] លីម បណ្តាលឲ្យឈ្មោះ [redacted] ស្រីខួច មើលឃើញថាមិនមែនជាប្តីរបស់ខ្លួន ក៏ស្រែកដាស់ប្តីឲ្យក្រោក ហើយបើកភ្លើងបន្ទប់ ក៏ឃើញឈ្មោះ [redacted] លីម កំពុងតែនៅពីលើឈ្មោះ [redacted] ស្រីខួច។ ក្រោយពីមានការដាក់ពាក្យបណ្តឹងពីជនរងគ្រោះ សមត្ថកិច្ចកងរាជអាវុធហត្ថបានធ្វើការឃាត់ខ្លួនជនសង្ស័យឈ្មោះ [redacted] លីម នៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០២០ និងកសាងសំណុំរឿងមកតុលាការ តែម្តង។

**នាពេលសវនាការ**

- ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ
- ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនរងគ្រោះ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិជនជាប់ចោទ
- ក្រោយពីបានស្តាប់សំណូមពរចុងក្រោយរបស់ជនជាប់ចោទ
- ក្រោយពីបានពិនិត្យឯកសារនានាដែលមានក្នុងសំណុំរឿង
- ក្រោយពីបានពិនិត្យ ពិភាក្សា និងពិចារណាត្រឹមត្រូវតាមច្បាប់

**សាលាដំបូងខេត្ត បន្ទាយមានជ័យ**

**យល់ឃើញថា**

- កាលពីថ្ងៃទី១៦ ខែមករា ឆ្នាំ២០២០ ពិតជាមានករណី **ប៉ុនប៉ងរំលោភសេពសន្ថវៈ** កើតឡើងនៅចំណុចការដ្ឋានសំណង់បុរីដួងច័ន្ទ ភូមិសាមគ្គីមានជ័យ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ប្រព្រឹត្តដោយឈ្មោះ [redacted] **លីម ហៅ អាថៃ** បានផឹកស្រាស្រវឹងចូលទៅដេកក្នុងបន្ទប់ជនរងគ្រោះ និងប្តីកំពុងដេកលក់ ហើយធ្វើសកម្មភាពប៉ុនប៉ងរំលោភសេពសន្ថវៈលើជនរងគ្រោះឈ្មោះ [redacted] ស្រីខួច ប៉ុន្តែជនរងគ្រោះដឹងខ្លួនទាន់ បានស្រែកឡើង ប្រាកដមែន។

- ជនជាប់ចោទឈ្មោះ [redacted] **លីម** បានឆ្លើយនាពេលសវនាការថា: នៅថ្ងៃកើតហេតុ ខ្លួនបានផឹកស្រាស្រវឹងខ្លាំង ហើយត្រូវបានមិត្តភក្តិជូនមកបន្ទប់ដេកវិញ ដោយខ្លួនបានចូលដេកក្នុងបន្ទប់របស់ខ្លួនដែលធ្លាប់ដេកកន្លងមក។ កន្លងមកខ្លួនធ្លាប់ដេកជាមួយមិត្តភក្តិម្នាក់ជាប្រុសដូចគ្នាឈ្មោះ **តុលា** និងធ្លាប់

លូកលេងប្រដាប់ភេទរបស់មិត្តភក្តិខ្លួនញឹកញាប់ ទើបនៅយប់កើតហេតុនោះ ខ្លួនបានដាក់ដៃលើពោះជនរងគ្រោះ ហើយបានស្ទាបចំប្រដាប់ភេទគេ ទើបដឹងថាជាមនុស្សស្រី ខ្លួនក៏ស្ទុះរត់ចេញពីបន្ទប់នោះ ក៏ត្រូវប្ដីគេចាប់តែម្ដង។ ខ្លួនពុំមានទូរស័ព្ទបញ្ចាំងភ្លើងមើលប្រដាប់ភេទជនរងគ្រោះ ហើយក៏មិនបានធ្វើសកម្មភាពស្ទាប និងជញ្ជក់ប្រដាប់ភេទគេដែរ។

- តាមអំណានចម្លើយជនរងគ្រោះឈ្មោះ [redacted] **ស្រីខូច** បានឆ្លើយបំភ្លឺថា: នៅថ្ងៃកើតហេតុនោះ ខ្លួននិងប្ដីកំពុងតែដេកក្នុងបន្ទប់ជាមួយគ្នា តែមិនបានដេកប៉ះគ្នាទេ។ ស្រាប់តែពេលនោះមានដៃមកអោបខ្លួនត្រឹមចង្កេះ តែខ្លួនមិនបានស្រែកទេ ដោយគិតថាជាប្ដីខ្លួន។ បន្ទាប់មកគេបានយកដៃលូកលេងប្រដាប់ភេទខ្លួន និងបានសើយរ៉ូបខ្លួនឡើងលើត្រឹមចង្កេះ និងបានរុញដៃគេចូលក្នុងប្រដាប់ភេទខ្លួន ហើយខ្លួនក៏មិនបានស្រែក ឬប្រកែកទេ ដោយគិតថាជាប្ដីដដែល។ បន្ទាប់មកគេបានយកទូរស័ព្ទមកបញ្ចាំងមើលប្រដាប់ភេទខ្លួន និងបានយកមាត់ជញ្ជក់ប្រដាប់ភេទខ្លួន រួចបំរុងដោះខោរខោគេ តែពេលនោះភ្លើងទូរស័ព្ទបានចាំងចំមុខគេ ទើបខ្លួនឃើញថាមិនមែនជាប្ដីខ្លួន ក៏ស្រែកដាស់ប្ដីអោយក្រោក បើកភ្លើងបន្ទប់ឡើងក៏ឃើញឈ្មោះ [redacted] **លីម** នេះនៅពីលើខ្លួនតែម្ដង។

- ជនជាប់ចោទព្យាយាមបដិសេធថាខ្លួនមិនមានបំណងប៉ុនប៉ងរំលោភសេពសន្ថវៈលើជនរងគ្រោះ គឺខ្លួនគ្រាន់តែបានដាក់ដៃចំពោះ និងចំប្រដាប់ភេទជនរងគ្រោះ ប៉ុណ្ណោះ ដោយខ្លួនយល់ច្រឡំថាជនរងគ្រោះជាមិត្តភក្តិឈ្មោះ **តុលា** ដែលតែងដេកជាមួយខ្លួន ហើយខ្លួនធ្លាប់លេងស្ទាបប្រដាប់ភេទរាល់យប់ ហើយខ្លួនក៏ពុំមានទូរស័ព្ទប្រើដែរ។ ការឆ្លើយបដិសេធរបស់ជនជាប់ចោទ មានភាពស្របគ្នាគ្រប់ដំណាក់កាល កន្លងមក ក៏ដូចជានាពេលសវនាការ បានឆ្លើយបដិសេធថាខ្លួនមិនបានប្រព្រឹត្តដូចជនរងគ្រោះចោទនោះទេ។ តុលាការនឹងពិចារណាបញ្ហានេះ។

- ជនរងគ្រោះឈ្មោះ [redacted] **ស្រីខូច** ក្រោយពីទទួលបានប្រាក់សំណង តាមកិច្ចព្រមព្រៀងប្រគល់ទទួល ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០ ជនរងគ្រោះឈ្មោះ [redacted] **ស្រីខូច** បានដកពាក្យបណ្ដឹងឈប់ប្ដឹង និងមិនបានចូលខ្លួនមកបំភ្លឺបញ្ជាក់អំពីការប្ដឹងចោទរបស់ខ្លួនអោយបានច្បាស់លាស់បន្ថែមទៀត តាមការកោះហៅឡើយ។

- តាមចម្លើយរបស់ជនជាប់ចោទ, ចម្លើយរបស់ជនរងគ្រោះ រួមទាំងឯកសារដែលមានក្នុងសំណុំរឿង មានភាពស៊ីសង្វាក់គ្នា បញ្ជាក់បានថា ជនជាប់ចោទឈ្មោះ [redacted] **លីម** គ្មានចេតនា ធ្វើសកម្មភាពប៉ុនប៉ងរំលោភសេពសន្ថវៈលើជនរងគ្រោះឡើយ។ អំពើរបស់ជនជាប់ចោទពុំមានធាតុផ្សំគ្រប់គ្រាន់ជាបទល្មើស **ប៉ុនប៉ងរំលោភសេពសន្ថវៈ** តាមបញ្ញត្តិមាត្រា២៧ និងមាត្រា២៣៩ នៃក្រមព្រហ្មទណ្ឌ ឡើយ។

- តាមចម្លើយរបស់ជនជាប់ចោទ, ចម្លើយរបស់ជនរងគ្រោះ រួមទាំងឯកសារដែលមានក្នុងសំណុំរឿង មានភាពស៊ីសង្វាក់គ្នា បញ្ជាក់បានថា កាលពីថ្ងៃទី១៦ ខែមករា ឆ្នាំ២០២០ ជនជាប់ចោទឈ្មោះ [redacted] **លីម** ពិតជាមានចេតនា និងបានធ្វើសកម្មភាពស្ទាបលើប្រដាប់ភេទរបស់ជនរងគ្រោះឈ្មោះ [redacted] ស្រីខូច នៅចំណុចការដ្ឋានសំណង់បុរីដួងច័ន្ទ ភូមិសាមគ្គីមានជ័យ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ប្រាកដមែន។ អំពើរបស់ជនជាប់ចោទនេះជាបទល្មើស **ប្រទូស្តកេរខ្មាស** បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមមាត្រា **២៤៦** នៃក្រមព្រហ្មទណ្ឌ។

- ឈ្មោះ [redacted] **ស្រីខូច** ជាជនរងគ្រោះមិនបានតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនៅចំពោះមុខ ចៅក្រមស៊ើបសួរ ក៏ដូចជានៅចំពោះមុខចៅក្រមជំនុំជម្រះនាពេលសវនាការដែរ ដោយបានដាក់ពាក្យសុំដក

ពាក្យបណ្តឹង ដោយមូលហេតុបានទទួលសំណងរដ្ឋប្បវេណី រួចហើយ។ ដូចនេះ តុលាការពុំគប្បីលើកបញ្ហាសំណងមកពិចារណា ឡើយ។

- តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា: ឆ្លងតាមការដេញដោល, តាមការស្តាប់អំណានចម្លើយជនរងគ្រោះ រួមទាំងឯកសារភស្តុតាងនានាក្នុងសំណុំរឿង ឃើញថាជនជាប់ចោទឆ្លើយបដិសេធថាខ្លួនមិនមានចេតនាធ្វើសកម្មភាពប៉ុប៉ងរំលោភសេពសន្ថវៈ លើជនរងគ្រោះទេ ខ្លួនគ្រាន់តែបានដាក់ដៃចំពោះនិងប៉ះចំប្រដាប់ភេទជនរងគ្រោះ ក៏ដឹងថាមិនមែនមិត្តភក្តិប្រុសឈ្មោះ **តុលា** ដែលធ្លាប់ដេកជាមួយ ក៏រត់ចេញពីបន្ទប់ភ្លាម។ ចម្លើយនេះផ្ទុយពីការរៀបរាប់របស់ជនរងគ្រោះទាំងស្រុង ដែលបានបញ្ជាក់ពីសកម្មភាពប្រព្រឹត្តរបស់ជនជាប់ចោទមកលើរូបខ្លួន រហូតឈានដល់ខ្លួនឃើញមុខច្បាស់ថាមិនមែនជាប្តីទើបស្រែកដាស់ប្តី ទើបជនជាប់ចោទរត់គេចខ្លួន។ ស្របគ្នានេះដែរ ភាគីខាងជនជាប់ចោទបានយល់ព្រមសងសំណងរដ្ឋប្បវេណីទៅជនរងគ្រោះផងដែរ។ តំណាងអយ្យការ យល់ឃើញថាមានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទ និងនៅតែរក្សាការចោទប្រកាន់លើឈ្មោះ [redacted] **លីម** ពីបទ **ប៉ុនប៉ងរំលោភសេពសន្ថវៈ** តាមបញ្ញត្តិមាត្រា២៧ និងមាត្រា២៣៩ នៃក្រមព្រហ្មទណ្ឌ ដដែល។ សូមអោយតុលាការពិចារណាផ្តន្ទាទោសតាមច្បាប់។

- មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទធ្វើសេចក្តីសន្និដ្ឋានស្នើសុំថា: ឆ្លងតាមការដេញដោល, តាមការស្តាប់អំណានចម្លើយជនរងគ្រោះ និងសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ ខ្លួនសូមធ្វើការជំទាស់លើការចោទប្រកាន់របស់តំណាងអយ្យការ ដោយហេតុថាកូនក្តីខ្លួនបានឆ្លើយថាគាត់គ្មានទូរស័ព្ទប្រើទេ មិនអាចមានអង្គហេតុនៃការធ្វើសកម្មភាពយកទូរស័ព្ទបើកពិលឈ្លបមើលប្រដាប់ភេទជនរងគ្រោះ ដូចជនរងគ្រោះឆ្លើយនោះទេ។ ជនរងគ្រោះក៏មិនបានចូលមកបំភ្លឺបញ្ជាក់អំពីការប្តឹងចោទប្រកាន់របស់ខ្លួន តាមការកោះហៅរបស់តុលាការឡើយ ផ្ទុយទៅវិញ មានតែចម្លើយរបស់កូនក្តីខ្លួនដែលបានបដិសេធរហូតមកគ្រប់ដំណាក់កាល។ កូនក្តីខ្លួនពិតជាមិនបានប៉ុនប៉ងរំលោភសេពសន្ថវៈលើជនរងគ្រោះដូចការចោទប្រកាន់ឡើយ កូនក្តីខ្លួនគ្រាន់តែបានដាក់ដៃប៉ះចំប្រដាប់ភេទជនរងគ្រោះប៉ុណ្ណោះ។ ស្នើសុំចៅក្រមសម្រេចកែប្រែបទចោទលើកូនក្តីខ្លួន ទៅជាបទ **ប្រទូសកេរ្តិ៍ខ្មាស** តាមមាត្រា ២៤៦ នៃក្រមព្រហ្មទណ្ឌ វិញ និងស្នើសុំអោយតុលាការពិចារណាសម្រេចបន្ធូរបន្ថយទោសដល់កូនក្តីខ្លួនផង។

- ជនជាប់ចោទឈ្មោះ [redacted] **លីម** សំណូមពរចុងក្រោយថា: សូមតុលាការជួយរកបន្ធូរបន្ថយទោសផង។

- គ្មានមានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] **លីម** (មានអត្តសញ្ញាណដូចខាងលើ) ពីបទ **ប៉ុនប៉ងរំលោភសេពសន្ថវៈ** ប្រព្រឹត្តនៅចំណុចការដ្ឋានសំណង់បុរីដួងច័ន្ទ ភូមិសាមគ្គីមានជ័យ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី១៦ ខែមករា ឆ្នាំ២០២០ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោស តាមបញ្ញត្តិមាត្រា ២៧ និងមាត្រា២៣៩ នៃក្រមព្រហ្មទណ្ឌ។

- មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] លីម (មានអត្តសញ្ញាណដូចខាងលើ) ពីបទ **ប្រទូស្តកេរខ្មាស** ប្រព្រឹត្តនៅចំណុចការដ្ឋានសំណង់បុរីដួងច័ន្ទ ភូមិសាមគ្គីមានជ័យ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី១៦ ខែមករា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោស តាមមាត្រា ២៤៦ នៃក្រមព្រហ្មទណ្ឌ។

Scanned with CamScanner

**ហេតុដូច្នេះសាលាដំបូងខេត្ត បន្ទាយមានជ័យ**
**វិនិច្ឆ័យសេចក្តី**

១- កែប្រែបទចោទលើឈ្មោះ [redacted]**លីម ហៅ អាចៃ** ភេទប្រុស កើតឆ្នាំ១៩៩២ ជនជាតិខ្មែរ (មានអត្តសញ្ញាណដូចខាងលើ) ពីបទ: **ប៉ុនប៉ងរំលោភសេពសន្ថវៈ** ប្រព្រឹត្តនៅចំណុចការដ្ឋានសំណង់បុរីដូងច័ន្ទ ភូមិសាមគ្គីមានជ័យ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី១៦ ខែមករា ឆ្នាំ២០២០ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **២៧** និងមាត្រា**២៣៩** នៃក្រមព្រហ្មទណ្ឌ មកជាបទ **ប្រទូស្តកេរខ្មាស** ប្រព្រឹត្តនៅចំណុចការដ្ឋានសំណង់បុរីដូងច័ន្ទ ភូមិសាមគ្គីមានជ័យ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី១៦ ខែមករា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **២៤៦** នៃក្រមព្រហ្មទណ្ឌ វិញ។

២- ផ្តន្ទាទោសឈ្មោះ [redacted]**លីម ហៅ អាចៃ** ភេទប្រុស កើតឆ្នាំ១៩៩២ ជនជាតិខ្មែរ (មានអត្តសញ្ញាណដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល **១ឆ្នាំ៦ខែ**។

ពីបទ: **ប្រទូស្តកេរខ្មាស** ប្រព្រឹត្តនៅចំណុចការដ្ឋានសំណង់បុរីដូងច័ន្ទ ភូមិសាមគ្គីមានជ័យ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី១៦ ខែមករា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **២៤៦** នៃក្រមព្រហ្មទណ្ឌ។

៣-សាលក្រមនេះ ជំនុំជម្រះនៅថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២០ និងប្រកាសសាធារណៈនៅថ្ងៃទី០៦ ខែសីហា ឆ្នាំ២០២០ ចំពោះមុខជនជាប់ចោទឈ្មោះ **ហេង លីម**។

បើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ** **ចៅក្រមប្រឹក្សា** **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

ហត្ថលេខា និងត្រា: [redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃព្រហស្បតិ៍ ២រោច ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
បន្ទាយមានជ័យ, ថ្ងៃទី០៦ ខែសីហា ឆ្នាំ២០២០
**ក្រឡាបញ្ជី**

បានឃើញ
**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**